**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០៩-១៦៧ ប្រ.ក

# ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មការរៀបចំទីផ្សារអន្តរធនាគារ និងប្តូរប្រាក់

---

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៩៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៨៩៧/០៣ ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ១៩៩៧ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងការប្តូរប្រាក់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការតែង តាំង ឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- យោងតាមការសំរេចរបស់អង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩

## ស ម្រេ ច

**ប្រការ ១.-**

បង្កើតគណៈកម្មការរៀបចំទីផ្សារអន្តរធនាគារ និងប្តូរប្រាក់ ដែលមានសមាសភាព ដូចខាងក្រោម:

| | | |
|---|---|---|
| ១. ឯកឧត្តម ជា ចាន់តូ | ទេសាភិបាល | ប្រធាន |
| ២. លោកជំទាវ នាវ ច័ន្ទថាណា | ទេសាភិបាលរង | អនុប្រធាន |
| ៣. លោកជំទាវ អ៊ុក ម៉ាលី | ទេសាភិបាលរង | អនុប្រធាន |
| ៤. លោកជំទាវ តាល់ ណៃអ៊ីម | អគ្គនាយក | សមាជិក |
| ៥. ឯកឧត្តម ស៊ុំ សន្និសិទ្ធ | អគ្គលេខាធិការ | សមាជិក |

៦. លោកស្រី ងួន សុខា អគ្គនាយករង សមាជិក

៧. លោក ហ៊ុយ ណារី អគ្គនាយករង សមាជិក ។

**ប្រការ ២.—**

គណៈកម្មការរៀបចំទីផ្សារអន្តរធនាគារ និងប្តូរប្រាក់មានមុខងារភារកិច្ច ដូចតទៅ :

- ពិនិត្យសម្រេចលើលទ្ធផលការងាររបស់គណៈកម្មការប្រតិបត្តិ រៀបចំទីផ្សារអន្តរធនាគារ និងប្តូរប្រាក់
- តាមដាន " ផែនការម៉ាក្រូ " និងធ្វើសេចក្តីសម្រេចចិត្ត ឬចាត់វិធានការឱ្យបានគ្រប់គ្រាន់នៅក្នុងករណីមានការពន្យារពេល ឬនៅពេលជួបប្រទះនឹងបញ្ហាផ្សេងៗ ។

**ប្រការ ៣.—**

គណៈកម្មការរៀបចំទីផ្សារអន្តរធនាគារ និងប្តូរប្រាក់ត្រូវប្រជុំរៀងរាល់ ២សប្តាហ៍ម្តង។

ប្រធានគណៈកម្មការអាចកោះប្រជុំនៅពេលណាក៏បាន និងអាចអញ្ជើញមន្ត្រីជំនាញពាក់ព័ន្ធផ្សេងទៀតឱ្យចូលរួមប្រជុំ តាមការចាំបាច់ ។

**ប្រការ ៤.—**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តនូវខ្លឹមសារនៃប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់ ។

**ប្រការ ៥.—**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ ៚

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ មិថុនា ឆ្នាំ ២០០៩

ទេសាភិបាល

ជា-ចាន់តូ

**<u>កន្លែងទទួល</u>**

- ដូចប្រការ ៤ " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារ

**<u>ចម្លងជូន</u>**

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"